# សង្ខេបប្រតិបត្តិ

## ១ សេចក្ដីផ្ដើម

បច្ចុប្បន្នតំបន់មួយចំនួននៃជាយរាជធានីភ្នំពេញ នៅបន្តខ្វះខាតថាមពលអគ្គិសនីប្រើប្រាស់ពេញ២៤ម៉ោង ខណៈតំបន់មួយចំនួនទៀតមានថាមពលអគ្គិសនីខ្សោយនៅឡើយ។ ប្រភពថាមពលអគ្គិសនី នាពេលបច្ចុប្បន្នមានប្រភពពីអនុស្ថានីយ៍ទី១ អនុស្ថានីយ៍ទី២ អនុស្ថានីយ៍ទី៣ អនុស្ថានីយ៍ទី៤ អនុស្ថានីយ៍ទី៥ អនុស្ថានីយ៍ទី៦ អនុស្ថានីយទី៧ ដែលស្ថិតក្នុងការគ្រប់គ្រងរបស់អគ្គិសនីភ្នំពេញរួមមាន រាជធានីភ្នំពេញ តំបន់ជាយក្រុង ជុំវិញរាជធានីភ្នំពេញ និងមានក្នុងទីប្រជុំជនខេត្តកណ្ដាល។

នៅឆ្នាំ២០១៣ តម្រូវការអានុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញគឺ ៤៩៤,៧០មេហ្គាវ៉ាត់។ ឯការផ្គត់ផ្គង់ថាមពលអគ្គិសនីពីការផលិតដោយរោងចក្រ និងការនាំចូលមកប្រព័ន្ធអគ្គិសនីភ្នំពេញបានកើនពី ២.៤៧៩,៧៣GWh ក្នុងឆ្នាំ២០១២ ទៅ ២.៧៥៧,៤២GWh ក្នុងឆ្នាំ២០១៣ ហើយការបាត់បង់ថាមពលនៅលើប្រព័ន្ធបានថយចុះពី ៨,៦៣ភាគរយក្នុងឆ្នាំ២០១២ ទៅ៨,២៣ភាគរយ ក្នុងឆ្នាំ២០១៣។

ដើម្បីធានានូវនិរន្តភាពនៃការអភិវឌ្ឍនេះ គម្រោងខ្សែបញ្ជូនអគ្គិសនីដែលមានតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍អគ្គិសនីស្ទឹងហាវ ទៅអនុស្ថានីយ៍ខាងលិចភ្នំពេញ ត្រូវរៀបចំផែនការនៃការប្រើប្រាស់ និងគ្រប់គ្រងដីឱ្យបានសមស្រប ហើយនឹងការយកចិត្តទុកដាក់ ចំពោះបញ្ហាប្រជាជននៅក្នុងតំបន់ប្រកបដោយតម្លាភាព និងគណនីយភាពត្រឹមត្រូវច្បាស់លាស់។ លើសពីនេះទៅទៀត គម្រោងត្រូវយកចិត្តទុកដាក់ទៅវិធានការការពារបរិស្ថាន ដោយតម្រូវឱ្យធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនៃគម្រោងជាមុន ដើម្បីបង្ហាញអំពីហេតុប៉ះពាល់ជា

វិជ្ជមាន និងអវិជ្ជមានរបស់គម្រោងព្រមទាំងផ្តល់នូវអនុសាសន៍ជូនដល់រាជរដ្ឋាភិបាល និងម្ចាស់គម្រោង ហើយនឹងត្រូវធ្វើការផ្សព្វផ្សាយដល់សាធារណៈជនឱ្យបានដឹងលឺផងដែរ។ ការវាយតម្លៃនេះ ត្រូវបានរៀបចំឡើងដោយ **ក្រុមហ៊ុន** Alex Corporation សហការជាមួយក្រុមហ៊ុន **គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** ក្រោមការត្រួតពិនិត្យយ៉ាងត្រឹមត្រូវពីក្រសួងបរិស្ថាន និងបណ្តាក្រសួងដែលពាក់ព័ន្ធមួយចំនួន។

## ២ ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

គម្រោងខ្សែបញ្ជូនអគ្គិសនី ដែលមានតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលពីអនុស្ថានីយ៍អគ្គិសនីស្ទឹងហាវ ទៅអនុស្ថានីយន៍អគ្គិសនីខាងលិចភ្នំពេញ ត្រូវគោរពទៅតាមក្របខណ្ឌច្បាប់មួយចំនួនដូចជា៖ (១)ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (២)ច្បាប់ស្តីពីព្រៃឈើ (៣)ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា (៤)ច្បាប់ភូមិបាល (៥)ច្បាប់ការងារ (៦)ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (៧)ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា (៨) អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (៩)អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (១០) អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (១១)គោលនយោបាយចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

## ៣ ការពិពណ៌នាអំពីគម្រោង

ក្រុមហ៊ុន Alex Corporation គឺជាក្រុមហ៊ុនមួយក្រៅស្រុកដោយធ្លាប់មានបទពិសោធន៍ និងមានឈ្មោះល្អ។ ក្រុមហ៊ុន Alex Corporation មានទីស្នាក់ការនៅជាន់ទី១៧ Phnom Penh Tower មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនឯកជន ទទួលខុសត្រូវលើការវិនិយោគនៃការអភិវឌ្ឍដែលមានដើមទុនវិនិយោគជាង **១១៩.១៤៦.០០០**USD ( **មួយរយដប់ប្រាំបួនលាន មួយរយសែសិបប្រាំមួយពាន់ដុល្លាអាមេរិក**) ដែលមាន **លោក ឡាវ អៀវចុង** ជាប្រធានក្រុមហ៊ុន។

ខ្សែបញ្ជូនអគ្គិសនី .ដែលមានតង់ស្យុងខ្ពស់២០៣គីឡូវ៉ុល ត្រូវបានស្នើឡើងដើម្បីសាងសង់បង្គោលអគ្គិសនី ចំនួន **៤២៦បង្គោល** ដែលមានប្រវែងសរុប **១៩៨គីឡូម៉ែត្រ**។ ខ្សែបញ្ជូនអគ្គិសនី

នេះ នឹងត្រូវតភ្ជាប់ ពីអនុស្ថានីយ៍អគ្គិសនី ដែលមានស្រាប់ **ស្ទឹងហាវ** ទៅអនុស្ថានីយ៍ដែលមានស្រាប់ **ខាងលិចភ្នំពេញ**។ គម្រោងតបណ្តាញអគ្គិសនីនេះ នឹងត្រូវឆ្លងកាត់ខេត្តចំនួនបី គឺខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តកំពង់ស្ពឺ។

- ខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់ភូមិសាស្ត្រខេត្តព្រះសីហនុចំនួន០៣ស្រុកគឺ ត្រង់ចំណុច **ស្រុកកំពង់សិលា ស្រុកស្ទឹងហាវ និងស្រុកព្រៃនប់ និងឃុំចំនួន៧**ដែលមានប្រវែងសរុបប្រមាណ **៧៧គីឡូម៉ែត្រ ស្មើនឹង៤៦បង្គោល**។

- ខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់ភូមិសាស្ត្រខេត្តកោះកុងមានចំនួន០១ស្រុកគឺ ត្រង់ចំណុច**ស្រុកស្រែអំបិល និងឃុំចំនួន១** ដែលមានប្រវែងសរុបប្រមាណ**២០គីឡូម៉ែត្រ ស្មើនឹង៧២បង្គោល**។

- ខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់ភូមិសាស្ត្រខេត្តកំពង់ស្ពឺមានចំនួន០៣ស្រុកគឺ ត្រង់ចំណុច**ស្រុកគងពិសី ស្រុកសំរោងទង** និង**ស្រុកភ្នំស្រួច និងចំនួនឃុំ១១** ដែលមានប្រវែងសរុបប្រមាណ **១០១គីឡូម៉ែត្រ ស្មើនឹង៣០៨បង្គោល**។

បង្គោលអគ្គិសនីនីមួយៗ នឹងត្រូវសាងសង់ក្នុងកម្ពស់ចាប់ពី ៣៦,៥១ម៉ែត្រ ទៅ៥២,៩៦ម៉ែត្រ ទៅតាមទីតាំងនៃប្រភេទបង្គោលនីមួយៗ។ ការសាងសង់បង្គោលអគ្គិសនី នឹងត្រូវរក្សាទុកចន្លោះពីបង្គោលមួយទៅបង្គោលមួយប្រវែងពី ២២០,១២ម៉ែត្រ ទៅ៤៩២,៥ម៉ែត្រ ហើយបង្គោលអគ្គិសនី នឹងត្រូវតំឡើងខ្សែទៅនឹងខ្សែចម្លង ACSA។

ការសាងសង់បង្គោលខ្សែបញ្ជូនអគ្គិសនីនេះ នឹងមានការបង្កើតសំណល់រឹង និងរាវមួយចំនួន ហេតុដូចនេះក្រុមហ៊ុនក៏មានផែនការដើម្បី គ្រប់គ្រងសំណល់រឹង-រាវ ទៅតាមគោលការណ៍ណែនាំស្តីអំពីការគ្រប់គ្រងសំណល់របស់ក្រសួងបរិស្ថាន។

# ៤ ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

## ៤.១ ធនធានរូបសាស្ត្រ

### ក. ប៉ាន់លេខា (រយៈកម្ពស់)

បង្គោលខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់ខេត្តកំពង់ស្ពឺមានចំនួន ៣០៨បង្គោល ចាប់ពីបង្គោលដែលមានរយៈកម្ពស់អប្បបរមាគឺ ១០ម៉ែត្រលើនីវ៉ូទឹកសមុទ្រ រយៈកម្ពស់អតិប្បរមាគឺ ១៦១ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។ រយៈកម្ពស់ជាមធ្យមគឺ ៦១,៨៣ម៉ែត្រលើនីវ៉ូទឹកសមុទ្រ និងមានរយៈកម្ពស់ជាស្តង់ដារគម្លាតគម្រូគឺ ៣៣,៨១ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។

### ខ. ភូគព្ភសាស្ត្រ

លទ្ធផលបានបង្ហាញថា ចាប់ពីបង្គោលខ្សែភ្លើងដំបូង (T001-WPP) រហូតដល់បង្គោលខ្សែភ្លើងចុងក្រោយ (T426-5TH) ត្រូវបានសាងសង់លើភូគព្ភសាស្ត្រចំនួន៤ប្រភេទ រួមមាន (១) Jurassic-Cretaceous Sandstone (២) Old Alluvium (៣) Young Alluvium និង(៤) Triassic Sandstone។

### គ. ប្រភេទដី

បង្គោលខ្សែបញ្ជូនអគ្គិសនីត្រូវបានសាងសង់លើប្រភេទដីចំនួន **៩ប្រភេទ** ផ្សេងៗគ្នា រួមមានប្រភេទដី Red-Yellow Podzols មានទំហំ២៩ហិកតា Acid Lithosols មានទំហំ២៥ហិកតា Grey Hydromorphics មានទំហំ១៧ហិកតា Coastal Complex មានទំហំ១៤ហិកតា Cultural Hydromorphics មានទំហំ១១ហិកតា Alluvial Lithosols មានទំហំ១០ហិកតា Planosols មានទំហំ៦ហិកតា Alumisols មានទំហំ៥ហិកតា និង Plinthite Podzols មានទំហំ៣ហិកតា។

### ឃ. ជលសាស្ត្រ

បង្គោលខ្សែភ្លើងចំនួន២០ ដែលស្ថិតនូវចន្លោះនៃការពង្រីក១០០ម៉ែត្រ រវាងអ័ក្សរបស់បង្គោលនឹងប្រព័ន្ធផ្លូវទឹក។ ក្នុងចំនោម ២០បង្គោលនោះមាន ៥បង្គោលដែលមានទីតាំងចម្ងាយ ៣០ម៉ែត្រជាប់នឹងប្រព័ន្ធផ្លូវទឹក នោះរួមមានបង្គោលលេខ (T348) បង្គោលលេខ (T371) ស្ថិតក្នុងឃុំបឹង

ព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង បង្គោលលេខ (T384) បង្គោលលេខ (T386) និងបង្គោលលេខ (T395-AP24) ដែលស្ថិតក្នុងឃុំសំរុង ស្រុកព្រៃនប់ ក្រុងព្រះសីហនុ។

## ៤.២ ការសិក្សាធនធានជីវសាស្ត្រ

### ក. ការសិក្សាគម្របព្រៃឈើ

តាមរយៈការវិភាគពង្រីក៣០ម៉ែត្រ សងខាងគន្លងខ្សែបញ្ជូន បានបង្ហាញថាគន្លងខ្សែបញ្ជូនឆ្លងកាត់ប្រភេទគម្របព្រៃឈើចំនួន ៦ប្រភេទផ្សេងៗគ្នា រួមមានប្រភេទគម្របព្រៃ ដីពុំមានគម្របព្រៃមានទំហំ៨៦៥ហិកតា ព្រៃល្បោះមានទំហំ ៤២ហិកតា ព្រៃស្រោងមានទំហំ៣៨ហិកតា ប្រភេទព្រៃផ្សេងៗមានទំហំ៣០ហិកតា ព្រៃគម្លោតបៃតងមានទំហំ១៧ហិកតា និងព្រៃពាក់កណ្តាលស្រោងមានទំហំ១៤ហិកតា។

### ខ. ការសិក្សាអំពីសត្វ

ការពិភាក្សាក្រុមចំនួន២ក្រុម នៅក្នុងភូមិស្ទឹងច្រាល និងភូមិទីប្រាំមួយ ដែលជាភូមិស្ថិតនៅជិតតំបន់យាយមៅដែលជាតំបន់ដែលនឹងមានគន្លងខ្សែឆ្លងកាត់ មានថនិកសត្វ១០ប្រភេទ ល្មូនមាន ៦ប្រភេទ បក្សី៨ប្រភេទ និងថលជលិកសត្វមាន ៤ប្រភេទ។

## ៤.៣ ការសិក្សាស្ថានភាពសង្គម-សេដ្ឋកិច្ច

តាមរយៈការសម្ភាសជាមួយប្រជាជនដែលរងការប៉ះពាល់ក្នុងឃុំទាំង១៩ បានបង្ហាញថាអ្នកឆ្លើយតបជាស្ត្រីមានប្រមាណ៣០ភាគរយ និងអ្នកឆ្លើយតបជាបុរសមានប្រមាណ៧០ភាគរយ។ លទ្ធផលនៃការសិក្សាបានបង្ហាញថា បុរសជាមេគ្រួសារមានប្រមាណ ៦០ភាគរយ និងស្ត្រីជាមេគ្រួសារមានប្រមាណ៤០ភាគរយ។

តាមរយៈលទ្ធផលនៃការសិក្សាបានបង្ហាញឲ្យឃើញថា មុខរបរចម្បងៗរបស់ប្រជាជនដែលបានសម្ភាសន៍រួមមាន អាជីវករមាន១៥,៤ភាគរយ ធ្វើស្រែមាន៥០,៦ភាគរយ អ្នកថម្ការមាន៧,៥ភាគរយ ចិញ្ចឹមសត្វមាន ៤,៧ភាគរយ កម្មករមាន១២,៤ភាគរយ មន្ត្រីរាជការមាន ២,៥ភាគរយ អ្នករត់ម៉ូតូឌុបមាន ៤,៨ភាគរយ និងអ្នកនេសាទមាន ២,១ភាគរយ ។ តាមរយៈលទ្ធផលនៃការសម្ភាស

គ្រួសារដែលរស់នៅក្បែរតំបន់គម្រោងអាចរកប្រាក់ចំណូលជាមធ្យមបាន ៧៧១.៤០០រៀល/ខែ (១៩២,៨៥ដុល្លា/ខែ)។ ចំពោះគ្រួសារអាចរកប្រាក់ចំណូលបានច្រើនបំផុតគឺ ២.៥៩២.៤០០រៀល/ខែ (៦៤៨,១ដុល្លា/ខែ) ហើយគ្រួសារដែលអាចរកប្រាក់ចំណូលតិចបំផុតគឺ ១២៨.៨០០រៀល/ខែ (៣២,២ ដុល្លា/ខែ)។ គម្លាតស្តង់ដារនៃប្រាក់ចំណូលរបស់គ្រួសារនីមួយៗគឺ ៥៥៤.៥០០រៀល/ខែ (១៣៨,៦៣ ដុល្លា/ខែ)។ ប្រជាជនដែលបានសម្ភាសន៍បានចំណាយប្រាក់សរុបជាមធ្យម ៦៧៣.៩០០រៀល/ខែ (១៦៨,៤៨ដុល្លា/ខែ)។ ចំពោះគ្រួសារដែលបានចំណាយប្រាក់តិចបំផុតគឺ ១២៦.០០០រៀល/ខែ (៣១,៥ដុល្លា/ខែ) និងគ្រួសារដែលបានចំណាយប្រាក់ច្រើនបំផុតគឺ ១.៣១៧.០០០រៀល/ខែ (៣២៩,២៥ដុល្លា/ខែ)។ គម្លាតស្តង់ដារនៃការចំណាយរបស់គ្រួសារនីមួយៗគឺ ២៩៧.០០០រៀល/ខែ (៧៤,២៥ ដុល្លា/ខែ)។

តាមលទ្ធផលនៃការសម្ភាសបានបង្ហាញថា កម្រិតអប់រំរបស់ប្រជាជនដែលរស់នៅក្បែរតំបន់គម្រោងនៅមានកម្រិតទាបនៅឡើយ។ កម្រិតអប់រំរបស់ប្រជាជនដែលមិនបានចូលរៀន ឬអនក្ខរកម្មមានចំនួន ៣៧ភាគរយ កម្រិតបឋមសិក្សាមានចំនួន ៤៧,៨ភាគរយ កម្រិតអនុវិទ្យាល័យមានចំនួន ១២ភាគរយ និងវិទ្យាល័យមានចំនួន ៣,៣ភាគរយ។

យោងតាមលទ្ធផលនៃការសម្ភាសបានបង្ហាញថា ប្រជាជនដែលមានលំនៅដ្ឋានក្បែរតំបន់គម្រោងបានប្រើប្រាស់ទឹកពីបួនប្រភពផ្សេងៗគ្នាគឺប្រភពទឹកទិញ ប្រភពទឹកអណ្តូង ប្រភពទឹកអូរ បឹង ស្ទឹង និងប្រភពទឹកពីបណ្តាញទឹកស្អាតឯកជន។ ប្រភពទឹកដែលប្រជាជនបានប្រើប្រាស់ច្រើនជាងគេគឺប្រភពទឹកភ្លៀង និងទឹកអូរ។ ប្រជាជនប្រមាណ ៦៧,៥ភាគរយ បានទាញយកទឹកភ្លៀងសម្រាប់ប្រាស់ចម្អិនម្ហូបអាហារ និងប្រជាជនប្រមាណ ៣០,៤ភាគរយ ទៀតបានទាញយកទឹកអូរ ឬស្ទឹងសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃដូចជាបោកគក់ ងូត និងលាងសម្អាតផ្សេងៗ។

ប្រជាជនដែលបានប្រើប្រាស់អុសធ្យូងមានចំនួន ៧២,៥ភាគរយ ប្រើប្រាស់ធ្យូងមានចំនួន ១២,៥ភាគរយ ប្រើប្រាស់ហ្គាសមានចំនួន ១០,៧ភាគរយ បានប្រើប្រាស់ហ្គាស និងប្រើប្រាស់ថាមពលអគ្គិសនីមានចំនួន ៤,៣ភាគរយ សម្រាប់ចម្អិនម្ហូបអាហារ។ ប្រជាជនដែលមានលំនៅដ្ឋានក្បែរតំបន់គម្រោង ប្រើថាមពលពីប្រភពម៉ាស៊ីនភ្លើងអគ្គិសនីផ្ទាល់ខ្លួន ភ្លើងអគ្គិសនីរដ្ឋ អាគុយ ចង្កៀងប្រេងកាត និងពិលអាគុយសម្រាប់បំភ្លឺក្នុងលំនៅដ្ឋានរបស់ខ្លួន។ ប្រជាជនដែលបានប្រើប្រាស់ថាម

ពលពីប្រភពថាមពលសម្រាប់បំភ្លឺលំនៅដ្ឋានរួមមានភ្លើងអគ្គិសនីផ្ទាល់ខ្លួនមានចំនួន៣,៦ភាគរយ ភ្លើងអគ្គិសនីរដ្ឋមានចំនួន ៨,៥ភាគរយ អាគុយមានចំនួន ៦៨,៥ភាគរយ ចង្កៀងប្រេងកាតមានចំនួន ១០,២ភាគរយ ពិលអាគុយមានចំនួន ៩,៣ភាគរយ និងថាមពលពន្លឺព្រះអាទិត្យមានចំនួន ១,៥ភាគរយ។

លទ្ធផលនៃការសម្ភាសបានបង្ហាញថា ៥១ភាគរយ នៃអ្នកឆ្លើយតបមានបង្គន់អនាម័យផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់។ ដោយឡែក ប្រជាជនប្រមាណ ៤៩ភាគរយ ទៀតមិនទាន់មានបង្គន់អនាម័យផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់នោះទេ។

តាមរយៈលទ្ធផលនៃការសម្ភាសបានបង្ហាញថា ៨៦,១ភាគរយ នៃអ្នកឆ្លើយតប ធ្លាប់បានឈឺ និងប្រជាជនប្រមាណ ១៣,៩ភាគរយទៀត បានឆ្លើយថាពួកគាត់មិនធ្លាប់ឈឺនោះឡើយ។ ប្រភេទជម្ងឺដែលប្រជាជនធ្លាប់ជួបប្រទះរួមមានជម្ងឺគ្រុនក្តៅ ផ្តាសាយ រាគរូស គ្រុនចាញ់ គ្រុនឈាម និងជម្ងឺសើស្បែកមួយចំនួនដូចជារមាស់ជាដើម។ តាមរយៈការសង្កេតរបស់ក្រុមសិក្សាស្រាវជ្រាវផ្នែកសេដ្ឋកិច្ច-សង្គមបានឲ្យដឹងថា ប្រភេទជម្ងឺដែលប្រជាជនធ្លាប់ជួបប្រទះនេះ គឺភាគច្រើនទាក់ទងទៅនឹងបញ្ហាអនាម័យផ្ទាល់ខ្លួន និងក្នុងគ្រួសារ។

ការគ្រប់គ្រងសំណល់រឹងប្រចាំថ្ងៃរបស់ប្រជាជនក្នុងតំបន់សិក្សា នៅមានកម្រិតទាបនៅឡើយ។ លទ្ធផលនៃការសម្ភាសបានបង្ហាញថា ប្រជាជនប្រមាណ ៧១,៣ភាគរយ បានបោះចោលសំណល់រឹងរាយប៉ាយនៅជុំវិញ ឬក្បែរផ្ទះ និងប្រជាជនប្រមាណ ២៨,៧ភាគរយទៀត បានដុតសំណល់រឹងដោយបើកចំហរនៅតាមទីវាល។ ជាមួយគ្នានេះ នៅក្នុងតំបន់សិក្សាពុំមានសេវាកម្មប្រមូលសំណល់រឹងនោះទេ។

តាមការអង្កេតផ្ទាល់ទៅលើទីតាំងសិក្សា ក្នុងឃុំទាំងពីរមិនមានប្រព័ន្ធលូបង្ហូរសំណល់រាវនោះទេ ពីព្រោះតំបន់សិក្សាជាតំបន់ជនបទ ដែលមិនទាន់មានការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រាវនៅឡើយ។ ជាក់ស្តែង តាមរយៈការសម្ភាសបានបង្ហាញថា ប្រជាជនក្នុងតំបន់ បានធ្វើការបង្ហូរសំណល់ពីផ្ទះបាយ សំណល់ពីបន្ទប់ទឹក សំណល់ពីបង្គន់ និងសំណល់ពីការបោកគក់របស់ខ្លួនទៅក្នុងប្រភពទឹកអូរ និងនៅតាមជុំវិញក្បែរផ្ទះ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ៥ ការចូលរួមជាសាធារណៈ

## ៥.១ ការពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ

តាមរយៈការប្រជុំពិភាក្សាពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុដែលមាន **ឯកឧត្តម ហេង សំអាន** អភិបាលរងខេត្តព្រះសីហនុ ជាគណៈអធិបតី បានបង្ហាញឲ្យឃើញថាការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញរបស់ក្រុមហ៊ុនទីប្រឹក្សាបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ប៉ុន្តែក៏នៅមានចំនុចមួយចំនួនត្រូវបំពេញបន្ថែមដូចខាងក្រោមៈ

- ការអូសខ្សែបញ្ជូនអគ្គិសនីនេះ អាចធ្វើឲ្យមានការប៉ះពាល់ដល់ព្រៃឈើ និងសត្វព្រៃក្នុងតំបន់ឧទ្យានជាតិ ហេតុដូចនេះក្រុមហ៊ុនត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីធ្វើសារពើភ័ណ្ឌព្រៃឈើ។
- ត្រូវកំណត់ទីតាំង និងចម្ងាយដែលប្រជាជនអាចសាងសង់លំនៅដ្ឋានបាន និងចម្ងាយរវាងផ្លូវនិងបង្គោលភ្លើងអោយបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្ងៃក្រោយ។
- ចំពោះផែនការបច្ចេកទេសនៃការគ្រប់គ្រងសំណល់ ត្រូវសិក្សាឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងរាល់ការបំពុលនានាទៅលើបរិស្ថាន និងប្រជាជនដែលនៅក្នុង និងក្បែរតំបន់គម្រោង។
- សូមអោយក្រុមហ៊ុនអភិវឌ្ឍន៍ រៀបចំអោយមាន Road of line ដើម្បីងាយស្រួលក្នុងការជួសជុលនៅថ្ងៃក្រោយ ហើយរាល់ការកំណត់ទីតាំងបង្គោលភ្លើង សូមអោយធ្វើយ៉ាងណាបញ្ចៀសពីតំបន់ដែលមានផលប៉ះពាល់តិចបំផុតពីគម្រោង។
- នៅក្នុងទីតាំងគម្រោងអូសខ្សែបញ្ជូនអគ្គិសនីនេះ នឹងមានការប៉ះពាល់ដល់ដីស្រែចម្ការ ផ្ទះសម្បែងប្រជាជន ហេតុដូចនេះ ក្រុមហ៊ុនត្រូវមានគោលការណ៍ដោះស្រាយជាមួយប្រជាជនឲ្យបានច្បាស់លាស់ និងសហការជាមួយអាជ្ញាធរ និងមន្ទីរដែលពាក់ព័ន្ធ ដើម្បីកុំឱ្យមានបញ្ហាទៅថ្ងៃក្រោយ។
- ចុងក្រោយអាជ្ញាធរខេត្តព្រះសីហនុ សូមធ្វើការគាំទ្រ និងជួយជម្រុញការអភិវឌ្ឍលើគម្រោងធ្វើខ្សែអគ្គីសនីនេះ ឱ្យដំណើរការបានយ៉ាងឆាប់រហ័ស។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## ៨.២ ការពិគ្រោះយោបល់នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ

តាមរយៈការប្រជុំពិភាក្សាពិគ្រោះយោបល់នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ ដែលមាន **ឯកឧត្តម ទី សំណាង** អភិបាលរងខេត្ត ជាគណៈអធិបតី បានបង្ហាញឱ្យឃើញថាការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញរបស់ក្រុមហ៊ុនទីប្រឹក្សាបានល្អប្រសើរ អាចទទួលយកបាន។ ខាងក្រោមមានចំនុចមួយចំនួនត្រូវបំពេញបន្ថែម ដែលជាសំណើពីខាងមន្ទីរពាក់ព័ន្ធរួមមាន៖

- ក្រុមហ៊ុនត្រូវគិតពីបញ្ហាបំពាក់ស្លាកសញ្ញាហាមឃាត់នៅតាមបង្គោល ឬខ្សែអគ្គិសនី ដើម្បីអោយប្រជាជនបានដឹងដែលអាចទប់ស្កាត់រាល់ការគ្រោះថ្នាក់ពីការឆក់អគ្គិសនី។
- ត្រូវបង្កើតវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ប្រជាជនអោយបានទូលំទូលាយចំពោះការសាងសង់គម្រោងនេះ និងផលប៉ះពាល់ជាយថាហេតុនៅថ្ងៃអនាគត។
- បង្គោលអគ្គិសនី គួរតែបំពាក់សំណាញ់ការពារហាមឃាត់មិនអោយក្មេងឡើងលេង និងបង្គោលដែលអាចនាំអោយឆក់ ឬធ្លាក់។
- ទាក់ទងនឹងសំណល់ដែលបញ្ចេញពីការសាងសង់ សូមអោយមានការគ្រប់គ្រងអោយបានល្អជាពិសេសប៉ះពាល់ដោយសម្លេងក្នុងពេលអនុវត្តន៍។
- យ៉ាងណាមិញ សូមអោយកាត់បន្ថយផលប៉ះពាល់ដល់តូចបំផុត ហើយបើប៉ះពាល់ដី ឬសម្បត្តិ ប្រជាជន សូមអោយមានការវាយតម្លៃអោយបានសមរម្យ និងអាចទទួលយកបានទាំងប្រជាជន និងក្រុមហ៊ុន។
- ហើយជាមតិចុងក្រោយអាជ្ញាធរ និងមន្ទីរដែលពាក់ព័ន្ធខេត្តកំពង់ស្ពឺ បានសំដែងនូវកិច្ចសហការ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្តគម្រោងខ្សែបញ្ជូនអគ្គិសនីនេះដែលជាចំណែកចូលរួមក្នុងការអភិវឌ្ឍប្រទេសផងដែរ។ គ្រប់មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរ បន្តចូល រួមសហការ និងគាំទ្ររាល់ការអនុវត្តគម្រោងនេះអោយបានរលូន និងឆាប់រហ័ស។

## ៨.៣ ការពិគ្រោះយោបល់ជាមួយប្រជាជន

តាមរយៈការសម្ភាសប្រជាជនដែលរងការប៉ះពាល់ក្នុងឆ្នាំ២០១៥ ដោយសារការសាងសង់ខ្សែបញ្ជូនអគ្គិសនីបានបង្ហាញថា មានប្រជាជនប្រមាណ៨១,៨១ភាគរយ គាំទ្រចំពោះ

គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី ខណៈពេលដែលប្រជាជនប្រមាណ១៨,១៩ភាគរយមិនគាំទ្រចំពោះគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីរបស់ក្រុមហ៊ុន Alex Corporation នេះ។

- ប្រជាជនខេត្តកំពង់ស្ពឺ មានការគាំទ្រ ៨១,១ភាគរយ ខណៈពេលដែលមាន១៨,៩ភាគរយមិនគាំទ្រចំពោះការអភិវឌ្ឍគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ។ ចំពោះខេត្តកោះកុងដោយសារគម្រោងឆ្លងកាត់ប្រមាណតែ២០គីឡូម៉ែត្រតែប៉ុណ្ណោះ តាមការសម្ភាសប្រជាជនបានបង្ហាញថា គាត់មានការគាំទ្រ១០០ភាគរយចំពោះគម្រោងនេះ។ រីឯខេត្តព្រះសីហនុតាមការសម្ភាសបានបង្ហាញថា មានប្រជាជន ប្រមាណ៩១,២១ភាគរយ បានគាំទ្រលើគម្រោង ខណៈពេលដែលមាន៨,៧៩ភាគរយ មិនគាំទ្រចំពោះការសាងសង់គម្រោងខ្សែបញ្ជូននេះ។

- ប្រជាជនដែលមានការគាំទ្រចំពោះការសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ ព្រោះគាត់គិតថាគម្រោងនេះនឹងបានផ្តល់ថាមពលអគ្គិសនីសម្រាប់ផ្គត់ផ្គង់តម្រូវការរបស់ប្រជាជន ដែលធ្វើឱ្យប្រជាជនងាយស្រួលក្នុងការរស់នៅ និងប្រកបមុខរបរផ្សេងៗ។ ចំពោះប្រជាជនដែលមិនគាំទ្រចំពោះគម្រោងនេះព្រោះគាត់គិតថា គម្រោងនេះនឹងធ្វើឱ្យមានការប៉ះដល់ទ្រព្យសម្បត្តិប្រជាជនដូចជាលំនៅដ្ឋាន ស្រែចម្ការរបស់ពួកគាត់ ម្យ៉ាងទៀតក៏ធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពប្រជាជនដែលរស់នៅក្បែរបង្គោលខ្សែបញ្ជូននេះផងដែរ។

## ៦ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ហេតុប៉ះពាល់បរិស្ថាន ដែលអាចកើតមានចំពោះគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីដែលមានតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល ពីអនុស្ថានីយ៍អគ្គិសនីស្ទឹងហាវ មកអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញ អាចកើតមានហេតុប៉ះពាល់បរិស្ថានមួយចំនួនដូចជាប៉ះពាល់សណ្ឋានដី ការហូរច្រោះដី ការខូចគុណភាពទឹក ការរំខានដោយសម្លេង និងរំញ័រ ធនធានសត្វព្រៃ និងព្រៃឈើ សុខភាពសាធារណៈ និងជាពិសេសប៉ះពាល់ដល់លំនៅដ្ឋាន និងស្រែចម្ការប្រជាជនដែលរស់នៅតាមគន្លងនៃខ្សែបញ្ជូនអគ្គិសនីនេះ។ តែទោះជាយ៉ាងណាក៏ដោយការប៉ះពាល់ទាំងនេះអាចជៀសវាងបានតាមរយៈវិធានការកាត់បន្ថយមួយចំនួន។ ទោះជាយ៉ាងនេះក្តី វត្តមាននៃការអភិវឌ្ឍនេះ ក៏នឹងអាចផ្តល់មកវិញនូវផលប្រយោជន៍ជាច្រើនដល់ប្រជាជនមូលដ្ឋាន និងប្រទេសជាតិទាំងមូលផងដែរតាមរយៈ៖

- ការបង្កើតឱកាសការងារ និងកាត់បន្ថយភាពខ្វះការងារធ្វើនៅក្នុងតំបន់ និងក្បែរតំបន់គម្រោងអភិវឌ្ឍន៍ និងជួយកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាជន ដែលអាចឈានដល់ការចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ។
- ចូលរួមអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់មានដូចជា ការពង្រីកបណ្តាញខ្សែបញ្ជូនអគ្គិសនី និងផ្លូវថ្នល់។
- បង្កើនការផ្គត់ផ្គង់អគ្គិសនីដល់ការប្រើប្រាស់ក្នុងគ្រួសារ ក៏ដូចជាការប្រើប្រាស់ក្នុងដំណើរការផលិតកម្មរបស់រោងចក្រសហគ្រាសនានា។
- រួមចំណែក ក្នុងការកាត់បន្ថយការកាប់ធនធានព្រៃឈើសម្រាប់ប្រើប្រាស់ក្នុងវិស័យថាមពល។
- រួមចំណែក លើកស្ទួយជីវភាពរបស់ប្រជាជននៅកម្ពុជាមួយកម្រិតទៀតតាមរយៈការកាត់បន្ថយការចំណាយនៃការប្រើប្រាស់អគ្គិសនីរបស់ពួកគាត់។
- រួមចំណែក បង្កើនចំណូលចូលរដ្ឋតាមរយៈការបង់ពន្ធនានា។
- រួមចំណែកជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិតាមរូបភាពផ្សេងៗ។ល។

## ៧ ផែនការគ្រប់គ្រងបរិស្ថាន

កម្មវិធីអង្កេតតាមដានគម្រោង គឺជាកម្មវិធីមួយសម្រាប់ធ្វើការត្រួតពិនិត្យ និងតាមដាននូវរាល់ហេតុប៉ះពាល់បរិស្ថានទាំងឡាយ ដែលអាចនឹងកើតមានឡើងដោយសារសកម្មភាពរបស់គម្រោងនៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោងដើម្បីផ្តល់ភាពងាយស្រួលឱ្យម្ចាស់គម្រោងរិះរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់ទាំងនោះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។

កម្មវិធីត្រួតពិនិត្យបរិស្ថាន (Environmental Monitoring Program) គឺជាកម្មវិធីមួយដែលម្ចាស់ក្រុមហ៊ុនត្រូវធ្វើការត្រួតពិនិត្យដោយខ្លួនឯងនៅគ្រប់វដ្តជីវិតរបស់គម្រោង ដើម្បីចូលរួមកាត់បន្ថយនូវហេតុប៉ះពាល់ដែលអាចកើតមានឡើង ដើម្បីចូលរួមចំណែកការថែរក្សានូវធនធានបរិស្ថាន ក៏ដូចជាការអនុវត្តនូវកិច្ចដំណើរការគម្រោងឱ្យមានស្ថេរភាព។ លទ្ធផលនៃការត្រួតពិនិត្យនេះ ម្ចាស់គម្រោង នឹងបញ្ជូនរបាយការណ៍ទៅអោយក្រសួងបរិស្ថានរៀងរាល់០៣ ខែម្តង។

# ៨ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ៨.១ សេចក្ដីសន្និដ្ឋាន

គម្រោងអភិវឌ្ឍន៍ខ្សែបញ្ជូនអគ្គិសនីដែលមានតង់ស្យុង **២៣០គីឡូវ៉ុល** ពីអនុស្ថានីយ៍ស្ទឹងហាវ ភ្ជាប់ទៅអនុស្ថានីយ៍នៅប៉ែកខាងលិចរាជធានីភ្នំពេញ ត្រូវឆ្លងកាត់ខេត្តចំនួនបីរួមមានខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តកំពង់ស្ពឺ។ ដើម្បីដំណើរការទៅបាន គម្រោងអភិវឌ្ឍន៍ខ្សែបញ្ជូនអគ្គិសនីរបស់ក្រុមហ៊ុន Alex Corporation ត្រូវចំណាយទុនវិនិយោគប្រមាណជាង **១១៩.១៤៦.000** USD ( **មួយរយដប់ប្រាំបួនលាន មួយរយសែសិបប្រាំមួយពាន់ ដុល្លារអាមេរិក**)។ គម្រោងខ្សែបញ្ជូនអគ្គិសនី ត្រូវបានស្នើឡើងដើម្បីសាងសង់បង្គោលអគ្គិសនីចំនួន **៤២៦បង្គោល** ដែលមានប្រវែងសរុប **១៩៨គីឡូម៉ែត្រ**។ ប្រាក់វិនិយោគក្នុងគម្រោងនេះត្រូវបានប្រើប្រាស់សម្រាប់ដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិការគម្រោង និងសម្រាប់ដោះស្រាយសំណងទៅកាន់គ្រួសារដែលទទួលរងការប៉ះពាល់។ នៅក្នុងដំណាក់កាលសាងសង់ ការអភិវឌ្ឍគម្រោងនេះ នឹងត្រូវការកម្លាំងពលកម្មទាំងក្នុង និងក្រៅស្រុកដែលតម្រូវការមានរហូតដល់៣០០នាក់ ទៅ៤០០នាក់ ក្នុងនោះមាន១០ភាគរយជាកម្លាំងពលកម្មជាជនបរទេស។

ការសិក្សាក៏បានកំណត់ឱ្យឃើញពីហេតុប៉ះពាល់នានា នៃការអនុវត្តគម្រោងលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គមផងដែរ។ ប៉ុន្តែហេតុប៉ះពាល់ជាអវិជ្ជមានទៅលើធនធានរូបសាស្ត្រ និងធនធានជីវសាស្ត្រគឺមានកម្រិតតិចតួចប៉ុណ្ណោះ។ រីឯស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជនរស់នៅក្បែរតំបន់គម្រោងនោះ គឺពុំមានផលប៉ះពាល់ធ្ងន់ធ្ងរណាមួយត្រូវបានរកឃើញឡើយ។

វត្តមានគម្រោងអភិវឌ្ឍន៍នេះ នឹងអាចរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាទាំងមូលតាមរយៈការអភិវឌ្ឍលើវិស័យថាមពលអគ្គិសនី និងការពង្រីកការផ្គត់ផ្គង់ថាមពល អគ្គិសនីបន្ថែមទៀតនៅតាមតំបន់ខ្វះខាតថាមពលអគ្គិសនីប្រើប្រាស់។ គម្រោងនេះទៀតសោត ក៏នឹងអនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្របនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនប្រកបដោយនិរន្តរភាព និងគោលនយោបាយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីផងដែរ។

## ៨.២ អនុសាសន៍

- តាមរយៈរបកគំហើញនៃការសិក្សារបស់ក្រុមហ៊ុនប្រឹក្សាយោបល់ យើងខ្ញុំសូមសំណូមពរដល់ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនានា មេត្តាជួយជ្រោមជ្រែង និងបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនអភិវឌ្ឍន៍ចំពោះគម្រោងខ្សែបញ្ជូនអគ្គិសនីរបស់ក្រុមហ៊ុន Alex Corporation ដើម្បីប្រតិបត្តិការគម្រោងតាមផែនការដែលបានកំណត់។ ហើយនិងសូមសំណូមពរដល់ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធជួយអនុវត្តន៍តាមដានត្រួតពិនិត្យការប្រតិបត្តិការគម្រោងរបស់ក្រុមហ៊ុនវិនិយោគនេះឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- ដោយឡែក ក្រុមហ៊ុន Alex Corporation ដែលនឹងប្រតិបត្តិការគម្រោងខ្សែបញ្ជូនអគ្គិសនីគប្បីត្រូវអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួននូវផែនការគ្រប់គ្រងបរិស្ថាន ដោយមានការតាមដានត្រួតពិនិត្យជាប្រចាំ និងគប្បីត្រូវមានកិច្ចសហការជាមួយមន្ត្រីនៃនាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ព្រមទាំងក្រសួង/ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី។ ជាពិសេសជាងនេះទៀតដើម្បីធានានូវសុវត្ថិភាព និងបញ្ចៀសនូវគ្រោះហានិភ័យដែលអាចកើតមានជាយថាហេតុដល់ប្រជាជនរស់នៅក្បែរតំបន់នោះ ក្រុមហ៊ុនគប្បីត្រូវដាក់ស្លាកសញ្ញាបញ្ជាក់គ្រោះថ្នាក់ឱ្យបានត្រឹមត្រូវ។ លើសពីនេះ ដើម្បីឆ្លើយតបនឹងការចូលរួមអភិវឌ្ឍន៍សង្គម និងធានាដល់ការលើកស្ទួយជីវភាពរបស់ប្រជាជន ក្រុមហ៊ុនគប្បីផ្តល់ឱកាសការងារដល់ប្រជាជនដែលរស់នៅក្បែរតំបន់គម្រោងនោះ ឱ្យបានច្រើនទៅតាមតម្រូវការរបស់ក្រុមហ៊ុន។

Draft